**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ....១១...សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំសិក្ខាសាលា អន្តរក្រសួង មហាផ្ទៃ និងសាធារណការ និងដឹកជញ្ជូន ស្តីពីការគ្រប់គ្រងសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរណ៍ផ្លូវគោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ ៦៨ ក្រ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- ពិនិត្យឃើញស្ថានភាពគ្រោះថ្នាក់ចរាចរនាពេលបច្ចុប្បន្នមានការកើនឡើង បណ្តាលឱ្យប៉ះពាល់ដល់អាយុជីវិត និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិសាធារណៈ

## សម្រេច

**ប្រការ១ :** បង្កើតគណៈកម្មការដើម្បីរៀបចំសិក្ខាសាលាអន្តរក្រសួង មហាផ្ទៃ និងសាធារណការ និងដឹកជញ្ជូន ស្តីពីការគ្រប់គ្រងសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- ឯកឧត្តម **ជុំ អឿក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ជាអនុប្រធាន |
| ៣- ឯកឧត្តម ឧត្តមសេនីយ៍ឯក **សូរ ផន** | អគ្គស្នងការរងទី ១ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | ជាសមាជិក |
| ៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ឹម សុផល** | អគ្គស្នងការរងនគរបាលជាតិ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៥- ឯកឧត្តម **ឡេង ធនយុទ្ធា** | អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ៦- លោក ឧត្តមសេនីយ៍ទោ **ណុប ស៊ីណា** | ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ ក្រសួងមហាផ្ទៃ | ជាសមាជិក |

www.pheakdeylaw.com

៧- លោក ឧត្តមសេនីយ៍ត្រី **ចំន្ទ ឫទ្ធី** ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ ក្រសួងមហាផ្ទៃ ជាសមាជិក

៨- លោក **អ៊ុំ ជុនឃា** ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

៩- លោក វរសេនីយ៍ឯក **ផូ ខន** អនុប្រធានទី ១ នាយកដ្ឋានសណ្តាប់ធ្នាប់ ក្រសួងមហាផ្ទៃ ជាសមាជិក

១០- លោក វរសេនីយ៍ឯក **ហ៊ឹម យ៉ាន** អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ក្រសួងមហាផ្ទៃ ជាសមាជិក

១១- លោក **ស្រី សិរីវឌ្ឍន៍** អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

១២- លោក **កែវ សារិន** អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

**ប្រការ២ :** ភារកិច្ចរបស់គណៈកម្មការនេះរួមមាន :

- រៀបចំទីកន្លែងប្រារព្ធពិធី កំណត់ពេលវេលា និងកម្មវិធីសិក្ខាសាលា
- រៀបចំខ្លឹមសារឯកសារនានា ដែលពាក់ព័ន្ធនឹងសិក្ខាសាលា
- រៀបចំពិធីការ បដិសណ្ឋារកិច្ច និងអញ្ជើញភ្ញៀវជាតិ និងអន្តរជាតិចូលរួមសិក្ខាសាលា
- រៀបចំសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់
- ធ្វើគំរោងចំណាយផ្សេងៗសម្រាប់បម្រើឱ្យកិច្ចដំណើរការសិក្ខាសាលា និងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច ។

**ប្រការ៣ :** - គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មការ ដើម្បីជាជំនួយការក្នុងការរៀបចំសិក្ខាសាលា
- សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ
- គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម អស់លោកដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ រហូតដល់ដំណើរការនៃសិក្ខាសាលានេះត្រូវបានបញ្ចប់ដោយជោគជ័យ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com